# បង្ការសត្វកណ្ដុរ
# កុំឲ្យមាននៅគេហដ្ឋានរបស់អ្នក



# ការណែនាំសម្រាប់
# ម្ចាស់គេហដ្ឋាននៅក្រុងឡូវែល

# មាតិកា


របៀបប្រើការណែនាំនេះ 1

តើសាលាក្រុងឡូវែលដោះស្រាយបញ្ហាកណ្ដុរដោយវិធីណា 1

របៀបទប់ស្កាត់កុំឲ្យមានកណ្ដុរ 2

ជំហានទី១៖ រកមើលដានកណ្ដុរ 2

ជំហានទី២៖ ចាត់ការបោសសម្អាត 4

លាងសម្អាតអាចម៍កណ្ដុរ និងដានវា 4

រើរបស់របរគរសំពីងសំពោងចេញ 4

គ្រប់គ្រងស្មៅចង្រៃ ព្រៃស៊ុបទ្រុប និងព្រៃ 5

ជំហានទី៣៖ ផ្ដាច់អាហារវា 6

គ្រប់គ្រងសម្រាមរបស់អ្នក 6

បំបាត់ប្រភពអាហារដទៃទៀត 6

ជំហានទី៤៖ បិទរន្ធវាឲ្យជិត 7

បិទស្នាមប្រេះ និងប្រហោងតូចៗ 8

បិទចន្លោះ និងរន្ធធំ 8

បិទរូងក្នុងដី 10

ជំហានទី៥៖ ចាត់ការបំបាត់វាចោលឲ្យអស់ 11

ដាក់ថ្នាំបំពុល 11

ជ្រើសរើស និងសហការគ្នាជាមួយក្រុមហ៊ុនគ្រប់គ្រងសត្វល្អិត 12

វិធីស្វែងរក្រុមហ៊ុនឲ្យត្រូវ 12

ការសហការធ្វើការជាមួយគ្នា 13

រឿងនិទៀន និងរឿងពិតអំពីសត្វកណ្ដុរ ក្របក្រោយ




## របៀបប្រើការណែនាំនេះ

**គ្មាននរណាម្នាក់ ចង់រស់នៅក្នុងសហគមន៍ជាមួយសត្វកណ្ដុរនោះទេ។ បើអ្នកឃើញសត្វកណ្ដុរនៅក្នុងតំបន់របស់អ្នក ឬទទួលបានសេចក្ដីជូនដំណឹងពីសាលាក្រុង ថាគេរកឃើញមានសត្វកណ្ដុរនៅកន្លែងរបស់អ្នក នោះការណែនាំនេះ គឺត្រូវសម្រាប់អ្នកហើយ។**

ដើម្បីប្រើការណែនាំនេះ៖

- ✓ អនុវត្តតាមជំហាននីមួយៗ ដើម្បីស្វែងរក និងចាត់ការសត្វកណ្ដុរឲ្យបាន និងលែងឲ្យមានសត្វទាំងនេះទៀត។
- ✓ ចូរចងចាំថា សត្វកណ្ដុរគឺជាបញ្ហារួមរបស់សហគមន៍។ ចូរពិភាក្សាជាមួយអ្នកជិតខាងរបស់អ្នក អ្នកជួលផ្ទះរបស់អ្នក ឬម្ចាស់ផ្ទះជួល ដើម្បីបង្ហាញការណែនាំនេះទៅពួកគាត់ និងសហការជាមួយពួកគាត់ ដោយធ្វើតាមជំហានទាំងនេះ។
- ✓ សូមចូលមើលគេហទំព័រនេះ៖ lowellma.gov/1689/Rodent-Control ឬទាក់ទងតាមអ៊ីម៉េលនេះ៖ rodents@lowellma.gov បើអ្នកមានសំណួរបន្ថែម។

**មធ្យោបាយពីរផ្លូវ ដែលអាចទាក់ទងសាលាក្រុងបាន៖**

- ទូរស័ព្ទទៅលេខនេះ៖ 978-674-4144
- អ៊ីម៉េលនេះ៖ Rodents@LowellMa.Gov

## វិធីដែលសាលាក្រុងឡូវែល ដោះស្រាយបញ្ហាសត្វកណ្ដុរ

ទីតាំងទ្រព្យសម្បត្តិសាធារណៈ ដូចជាឧទ្យាន អគារក្រុង លូទឹកស្អុយសាធារណៈ គឺស្ថិតក្រោមការត្រួតពិនិត្យជាប្រចាំ ហើយសត្វល្អិតត្រូវចាត់ការកម្ចេចចោល តាមរយៈនាយកដ្ឋានសាធារណការរបស់ក្រុងឡូវែល។

នាយកដ្ឋាននេះ ក៏មានកម្មវិធីជំនួយគ្រប់គ្រងសត្វចង្រៃតាមគេហដ្ឋានផងដែរ ដែលកម្មវិធីនេះផ្ដល់នូវការចុះត្រួតពិនិត្យសត្វចង្រៃដោយឥតគិតថ្លៃ និងដាក់ថ្នាំពុលកម្ចាត់សត្វទាំងនោះ នៅលើទីតាំងដែលមានម្ចាស់គ្រប់គ្រង នៅក្នុងក្រុងឡូវែល។

សូមទាក់ទង៖ **rodents@lowellma.gov** បើអ្នកឃើញសត្វកណ្ដុរ ឬដានកណ្ដុរនៅកន្លែង ឬអគារសាធារណៈ ឬកន្លែងអាជីវកម្មណាមួយ។

## របៀបគ្រប់គ្រងសត្វកណ្ដុរ

ដើម្បីគ្រប់គ្រងសត្វកណ្ដុរ អ្នកត្រូវរើចោលអ្វីក៏ដោយដែលសត្វនេះត្រូវការ ដើម្បីវារស់បាន ដូចជាចំណីអាហារ ទឹក ជម្រក និងមធ្យោបាយដែលឲ្យវារត់ចុះឡើងបាន។

## ជំហានទី១៖ រកមើលដាន







- ចូររកមើលកន្លែងណាដែលសត្វកណ្ដុររស់នៅ។ សត្វនេះភាគច្រើនរស់តាមរូងក្នុងដី។ រូងនេះជារន្ធក្នុងដី ឬក្នុងប៉េតុង ដែលមានមុខកាត់ពី ១ ទៅ ៤អ៊ីញ ដោយមានគែមរលោង។ រូងទាំងនេះ មាននៅក្រោមព្រៃស៊ុបទ្រុប និងកូនឈើ។ ជារឿយៗ រន្ធបែបនេះមានច្រើនជាងមួយ។
- ចូររកមើលអាចម៍វា។ អាចម៍ទាំងនេះ ច្រើនតែមាននៅក្បែរសម្រាម។ បើអាចម៍នោះសើម និងខ្មៅ នោះជាសញ្ញាណប្រាប់ថាកន្លែងនោះមានសត្វកណ្ដុរហើយ។
- ចូររកមើលរន្ធ និងស្នាមកកេរលើឈើ និងធុងសម្រាមធ្វើពីជ័រ។
- ចូរមើលតាមជញ្ជាំង និងស្មៅ ដើម្បីរកមើលដានជើងវារត់។ សត្វកណ្ដុររត់តាមផ្លូវដដែល ច្រើនដងក្នុងមួយថ្ងៃៗ ដោយបន្សល់ស្នាមដានជើងខ្មៅរាងរអិលដូចខ្លាញ់នៅតាមជញ្ជាំង និងដានលើវាលស្មៅដែលងាប់។



សត្វកណ្ដុរចេញពេលយប់។ ដូច្នេះចូរដើរខាងក្រៅផ្ទះ ដោយមានកាន់ពិលបំភ្លឺ ក្រោយថ្ងៃលិច។
ធ្វើដូច្នេះនឹងជួយឲ្យអ្នកឃើញកន្លែងដែលកណ្ដុររត់ចេញចូល ដើម្បីអ្នកអាចរកមើលរូងក្នុងដីនៅពេលភ្លឺ។



## ជំហានទី២៖ ចាត់ការបោសសម្អាត

### ចូរលាងសម្អាតអាចម៍កណ្តុរ និងស្នាមដានជើងវា

**សត្វកណ្តុរទាក់ទងគ្នា និងបបួលគ្នាវាបាន តាមរយៈទឹកនោម និងអាចម៍របស់វានេះឯង។**

- ចូរបោសសម្អាតអាចម៍កណ្តុរ និងលាងជម្រះស្នាមដានជើងវាដែលជិតខ្មៅរលោងដូចខ្លាញ់។ ចូរលាងសម្អាតម្តុំនោះដោយប្រើទឹក និងលាយទឹកអូសាវ៉ែលស្រាល (bleach) ដោយប្រើទឹកដប់ អូសាវ៉ែលមួយ។
- ចូរពិភាក្សាជាមួយអ្នកជិតខាងរបស់អ្នក និងសហការគ្នាលាងសម្អាត ដើម្បីកុំឲ្យកណ្តុរផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតបាន។

### រើរបស់របរគរសំពឹងសំពោងចោល

**របស់របរសំពឹងសំពោង ជាសម្បុកកណ្តុរ ដើម្បីឲ្យវាអាចលាក់ខ្លួន ដេក និងបន្តពូជ។**

- ចូររើ (និងយកទៅ recycle) គំនរកាសែត ថង់ក្រដាស កេសក្រដាស និងដប។
- សម្អាតអគារក្រោមដី (basement) និងក្រោយផ្ទះរបស់អ្នក។
- ចូរដាក់របស់របរឲ្យឆ្ងាយពីជញ្ជាំង និងកុំដាក់ផ្ទាល់ដី។





## គ្រប់គ្រងស្មៅចង្រៃ ព្រៃស៊ុបទ្រុប និងព្រៃ

**សត្វកណ្ដុរជារឿយៗ គេឃើញមាននៅក្នុងរូងក្នុងដី ក្រោមព្រៃស៊ុបទ្រុប និងកូនឈើ។**



- ចូរធ្វើយ៉ាងណា ដាំស្មៅខ្ពស់ៗ ព្រៃ និងឈើស៊ុបទ្រុប ឲ្យឆ្ងាយពីគ្រឹះអគារ។ បោចដើម អាយវី (ivy) នៅជុំវិញរូងក្នុងដី។
- ចូរលៃយ៉ាងណាទុកដីទំនេរ ៦អ៊ីញពីអគារ និងត្រូវកាត់តម្រឹមព្រៃស៊ុបទ្រុប។
- ចូរទុកចន្លោះពីដើមរុក្ខជាតិមួយទៅដើមមួយទៀត និងចូរកុំដាំដំណាំប្រច្រុះប្រច្រៀតគ្នាខ្លាំងពេក។
- ចូរថៃស្មួនដំណាំកុំឲ្យមានស្មៅ និងសម្រាម។



## ជំហានទី៣៖ ផ្តាច់អាហារវា

**សត្វកណ្តុរត្រូវការអាហារមួយអោនស៍ មួយថ្ងៃ។ សូមកុំធ្វើឲ្យសម្រាមរបស់អ្នកក្លាយជាចំណីអាហាររបស់សត្វកណ្តុរ។**

### គ្រប់គ្រងសម្រាមរបស់អ្នក

- ចូរដាក់សម្រាមក្នុងធុងសម្រាម *ជានិច្ច* ហើយគ្របធុងនោះឲ្យជិតល្អ។
- ចូរដាក់សម្រាមក្នុងធុងសម្រាមក្រៅផ្ទះ ឲ្យនៅកៀកជិតថ្ងៃគេប្រមូលសម្រាមបំផុត បើអាចធ្វើបាន។ ការទុកសម្រាមចោលនៅខាងក្រៅច្រើនយប់ គឺដូចដាក់ហៅសត្វកណ្តុរ។
- ចូរលៃលកឲ្យមានធុងសម្រាមគ្រប់គ្រាន់ សម្រាប់ដាក់ទុកដាក់សម្រាម ពេលរង់ចាំគេមកដឹកនោះ។
- ចូរប្រើធុងសម្រាមធ្វើពីជ័រស្វិត ឬដែកដែលមានគម្របបិទជិតល្អ។



### បំបាត់ប្រភពអាហារដទៃទៀត

- ចូរទុកដាក់ម្ហូបអាហារនៅក្នុងប្រអប់ដែលបិទជិតត្រឹមត្រូវ។
- ចូរកុំដាក់ម្ហូបអាហារចោលក្នុងចាន ទុកឲ្យឆ្មាអានាថា ឬសត្វព្រាប ឬសត្វកំប្រុក ជាពិសេសដាក់ទុកចោលមួយយប់។
- ចូររើសគ្រាប់ចំណីសត្វ ដែលជ្រុះពីអ្នកបាចឲ្យសត្វស៊ីលើដី។ ចូររើសវាឲ្យអស់នៅពេលយប់ ឬយកល្អគួរចៀសវាងបាចគ្រាប់ចំណីសត្វឲ្យសត្វស៊ីបែបនេះ។

## ជំហានទី៤៖ បិទរន្ធវាឲ្យជិត

សត្វកណ្ដុរកកេរឲ្យធ្លុះជារន្ធចូលក្នុងអគារ និងអាចវារចូលតាមកន្លែងប្រេះតូចចង្អៀតត្រឹមកន្លះអ៊ីញ។ ដើម្បីលែងឲ្យសត្វកណ្ដុរចូលរួច ចូរបិទប្រហោ និងស្នាមប្រេះទាំងអស់ដែលមាននៅគ្រឹះអគារ តាមជញ្ជាំង លើដី ក្រោមមាត់ទ្វារ និងនៅជុំវិញមាត់បង្អួច។ ការជួសជុលបែបនេះ ភាគច្រើនអាចធ្វើបាន ដោយបុគ្គលិកផ្នែកជួសជុលនិងថែទាំ នាយកសាលា ជាង ឬអ្នកជំនាញផ្នែកគ្រប់គ្រងសត្វល្អិត។ សម្ភារៈទាំងនេះ មិនថ្លៃទេ ហើយអាចងាយរកបានស្ទើរតែគ្រប់ហាងលក់គ្រឿងផ្ទះ និងអគារ។



## បិទស្នាមប្រេះ និងប្រហោងតូចៗ



- បិទស្នាមប្រេះ និងប្រហោងតូចៗ ដោយប្រើកាវ ឬប្រើស៊ីម៉ង់ត៍បិទដំបូល។ របស់នេះធន់បានយូរ និងងាយបូកនិងបិទ ដោយប្រើកាំភ្លើងបាញ់កាវ។
- បិទចន្លោះប្រហោងក្រោមទ្វារ ដោយប្រើអំបោសដែកការពារសត្វចង្រៃ។
- បិទចន្លោះប្រហោងបង្អួច ដោយប្រើដែកកែង។
- បិទសំណាញ់លើប្រហោងខ្យល់ចេញចូល ជាពិសេសនៅលើជាន់ផ្ទាល់ដី។

## បិទចន្លោះ និងរន្ធធំ

**វិធីបិទចន្លោះ និងរន្ធធំ គឺអាស្រ័យលើសម្ភារៈអគារ និងទំហំនៃចន្លោះនៅក្រោយរន្ធនោះ។**



- ចូរប្រើបាយអ ឬស៊ីម៉ង់ត៍លាយស្រេច ដើម្បីបិទចន្លោះ និងរន្ធនៅក្នុងស៊ីម៉ង់ត៍ និងថ្មនៅបាតអគារនោះ។ ចូរដាក់សំណាញ់ដែកបិទរន្ធធំ ឬរ៉ែងដែក រួចបិទដោយបាយអ ឬស៊ីម៉ង់ត៍។
    - សំណាញ់ដែកនេះ អាចយកមកដាក់នៅតាមជើងរបង ឬរានហាល និងដាក់កប់ឲ្យចូលក្នុងដីជម្រៅប្រមាណ ១៨អ៊ីញ ដើម្បីការពារកុំឲ្យសត្វចង្រៃកាយរូងបាន។



- ចូរបិទគម្របលូទឹកស្អុយនៅលើដី និងមុខបើកខ្យល់ចេញចូលនោះ ដោយប្រើសំណាញ់ដែករឹង និងដំដែកគោល ឬបិទស៊ីម៉ង់ត៍ឲ្យជាប់។

- ចូរដាក់បន្ទះដែក នៅផ្នែកខាងក្រោមរបស់មាត់ទ្វារ គឺដាក់ពីខាងក្រៅ កន្លែងដែលកណ្ដុរកកេរ និងកន្លែងដែលកណ្ដុរវារចូលក្នុងអគារនោះ។ ចូរក្រាលបន្ទះដែកនៅក្រោមនោះ។



- នៅក្រោមអំបោសដែកដែលដាក់លើមាត់ទ្វារនោះ ចូរប្រើអំបោសដែកយ៉ាងណា ដែលទុកចន្លោះនៅក្រោមទ្វារនោះ ឲ្យតូចជាង ០.២៥ អ៊ិញ។



- ចូរគិតគូដាក់បន្ទះដែករឹង នៅចន្លោះគ្រឹះអគារ និងដី។



- ចូរបិទបំពង់ដែលចោះចូលជញ្ជាំង ដោយប្រើបន្ទះដែក(ឬ pipe collars)។ ចូលពិនិត្យមើលបំពង់ទឹកនោះជាប្រចាំ ក្រែងមានលិច។



## បិទរូងក្នុងដីដែលអត់មានសត្វ

**រូងដែលគ្មានសត្វនៅ ជារឿយៗនឹងមានស្លឹកឈើជ្រុះចូល ឬមានសម្បុកពីងពាង ឬមានសម្រាមនៅក្បែរមាត់រូងនោះ។ គួរបិទរូងនេះចោល ដើម្បីកុំឲ្យសត្វកណ្ដុរអាចចូលទៅវិញបាន។**



- បិទរូងក្នុងដី ដោយចាក់ដីបំពេញ និងបង្ហាប់វាដោយប្រើប៉ែល ឬជើងជាន់។



- ចូរបិទរូង ដែលមានក្នុងស្នាមប្រេះ ឬផ្លូវដើរដែលបែក ដោយប្រើស៊ីម៉ង់ត៍ ឬការបិទដែក។



# ជំហានទី៥៖ ចាត់ការកម្ចាត់វាឲ្យអស់

## ការដាក់នុយបំពុលសត្វចង្រៃ

**ការដាក់នុយបំពុលនេះ គឺជាវិធីដ៏មានប្រសិទ្ធភាព ក្នុងការកម្ចាត់សត្វកណ្ដុរឲ្យអស់។ ប៉ុន្តែការប្រើថ្នាំពុលនេះ ធ្វើបានទាល់តែអ្នកនោះជាអ្នកជំនាញអាជីព។ ថ្នាំពុលនេះ បើប្រើត្រឹមត្រូវតាមក្បួន គឺមានផលប៉ះពាល់ពាល់ដល់មនុស្ស និងសត្វតិចតួចបំផុត។ ដូច្នេះជាការល្អ គួរជួលនរណាម្នាក់ ដែលបានឆ្លងកាត់វគ្គបណ្ដុះបណ្ដាលត្រឹមត្រូវ បើអាចធ្វើទៅបាន។ ហើយចូរចាំថា ការកម្ចាត់សត្វចង្រៃដោយប្រើថ្នាំពុលនេះ គឺគ្រាន់តែជាផ្នែកមួយនៃដំណោះស្រាយផ្សេងៗច្រើនផ្លូវទៀតតែប៉ុណ្ណោះ! សូមធ្វើតាមដំបូន្មានផ្សេងៗទៀត នៅក្នុងការណែនាំនេះ ដើម្បីធ្វើយ៉ាងណាចាត់ការកម្ចាត់សត្វកណ្ដុរឲ្យអស់។**

**ចូរធ្វើយ៉ាងណា ឲ្យក្រុមហ៊ុនគ្រប់គ្រងសត្វល្អិតរបស់អ្នក អនុវត្តតាមការណែនាំនេះ៖**

- ចូរអាន និងអនុវត្តតាមស្លាកសញ្ញាណែនាំរបស់ក្រុមហ៊ុនផលិត និងប្រើប្រាស់ថ្នាំពុលក្នុងបរិមាណតិចតួចបំផុត។ អ្នកត្រូវធ្វើយ៉ាងណា ឲ្យមានសញ្ញាណែនាំនោះនៅក្នុងដៃអ្នកមួយច្បាប់ដែរ។
- ចូរប្រើស្រោមដៃដែលប្រើម្ដងរួចបោះចោល នៅពេលកាន់ថ្នាំពុល និងលាងដៃក្រោយប៉ះពាល់វា។



- ចូរប្រើប្រអប់ម្យ៉ាង ដែលអាចដាក់ថ្នាំពុលខាងក្នុង។ ដាក់ប្រអប់នោះនៅផ្ទាល់ដី ឬបូកស៊ីម៉ង់ត៍ឲ្យជាប់ ឬបិទការ ឬចងខ្សែ។
- ចូរដាក់ប្រអប់ថ្នាំពល់នេះ នៅលើផ្លូវដដែលដែលកណ្ដុររត់។ ជារឿយៗផ្លូវបែបនេះ គឺមាននៅតាមបណ្ដោយជញ្ជាំងអគារ និងជួររបង។ ដោយសារតែកណ្ដុររត់តែតាមផ្លូវដដែល វាទំនងជាស៊ីថ្នាំពុលដែលដាក់ក្នុងអង្គប់ ដែលដាក់នៅតាមផ្លូវវានោះ។



- ចូរប្រើជីវឡាវ ដើម្បីដាក់គ្រាប់ថ្នាំពុល ចូលទៅក្នុងរូងក្នុងដី។ ធ្វើបែបនេះ គឺដើម្បីប្រាកដថាគ្រាប់ថ្នាំពុលនោះ ធ្លាក់ចូលជ្រៅទៅក្នុងរូង ដើម្បីកុំឲ្យសត្វកណ្ដុរអាចរុញវាចេញវិញបាន។
- ថ្នាំពុលដែលច្រកថង់ មិនគួរប្រើនៅក្នុងរូងដីទេ ឬមិនគួរប្រើក្នុងអង្គប់នោះដែរ។ កណ្ដុរអាចរុញ ឬពាំវាចេញក្រៅរូងដី ឬអង្គប់ ដែលនាំឲ្យកូនក្មេង ឬសត្វចិញ្ចឹម ឬ សត្វព្រៃដទៃ អាចប៉ះពាល់វា។

- ចូររក្សាទុក និងដាក់ប្រអប់ដាក់នុយថ្នាំពុល នៅកន្លែងណាដែលសត្វចិញ្ចឹម និងកូនក្មេងយកវាមិនបាន។
- ហាមប្រើផលិតផលណាដែលគ្មានលេខចុះបញ្ជីរបស់ទីភ្នាក់ងារការពារបរិស្ថានអាមេរិក (EPA) ។
- ចូរផ្លាស់នុយថ្នាំបំពុលនោះ ក្រោយកណ្ដុរស៊ីអស់។
- ចូរទុកប្រអប់ និងនុយបំពុលនោះ នៅមួយកន្លែង ឲ្យបានយ៉ាងហោចណាស់ពីរសប្ដាហ៍ ក្រោយលែងមានសកម្មភាពកណ្ដុរ។ ចូរសង្កេតតាមដានមើលសកម្មភាពនេះជាប្រចាំ រាល់ខែ។
- ហាមប្រើប្រាស់នុយបំពុលដែលមិនស្របច្បាប់។



**សម្រាប់ព័ត៌មានបន្ថែមអំពីថ្នាំសម្លាប់សត្វល្អិត សូមទូរស័ព្ទទៅមជ្ឈមណ្ឌលព័ត៌មានអំពីសត្វល្អិតជាតិ តាមលេខនេះ៖ (800) 858-7378។**

## ការជ្រើសរើស និងសហការជាមួយក្រុមហ៊ុនគ្រប់គ្រងសត្វល្អិត

មិនមែនឲ្យតែក្រុមហ៊ុនគ្រប់គ្រងសត្វល្អិតទាំងអស់ សុទ្ធតែបានឆ្លងកាត់ការបណ្ដុះបណ្ដាលផ្នែកគ្រប់គ្រងសត្វកណ្ដុរនោះទេ។ ដើម្បីកម្ចាត់សត្វកណ្ដុរ អ្នកត្រូវតែជ្រើសរើសក្រុមហ៊ុនឲ្យត្រូវ ដោយត្រូវឲ្យមានភាពប្រាកដអំពីអ្វីដែលអ្នកចង់បាន និងត្រូវពិនិត្យមើលការងាររបស់ក្រុមហ៊ុននោះ។

## របៀបរកក្រុមហ៊ុនឲ្យត្រូវ

**ដើរសួរគេឯង និងសម្ភាសក្រុមហ៊ុន**

- ចូរសួរអ្នកជិតខាងរបស់អ្នក និងមិត្តភក្តិក្រែងគេស្គាល់ក្រុមហ៊ុនទាំងនោះ។
- ចូររកមើលក្នុងសៀវភៅបញ្ជីលេខទូរស័ព្ទ និងតាមអនឡាញ ដើម្បីរកមើលសេវាផ្នែកគ្រប់គ្រងសត្វល្អិត **“integrated pest management”**។ ក្រុមហ៊ុនទាំងនេះ ទំនងជាអាចចុះធ្វើអធិការកិច្ច តាមដាន និងផ្ដល់អានុសាសន៍ និងជួសជុល។
- ចូរសម្ភាសក្រុមហ៊ុន។ សួររកព័ត៌មាន រួមទាំងព័ត៌មានអំពីអតិថិជនពីមុនដែលក្រុមហ៊ុនទាំងនេះធ្លាប់ផ្ដល់សេវា។
- ចូរសួររកព័ត៌មានឲ្យប្រាកដថា អ្នកបច្ចេកទេសនោះ មានអាជ្ញាប័ណ្ណផ្នែកគ្រប់គ្រងសត្វល្អិតពីរដ្ឋម៉ាសាឈូសេត។ ចូររក្សាទុកអាជ្ញាប័ណ្ណនោះមួយច្បាប់ សម្រាប់រយៈពេលដែលក្រុមហ៊ុននេះកំពុងបំពេញការងារលើដីរបស់អ្នក។ ដើម្បីរកមើលអាជ្ញាប័ណ្ណណាមួយ សូមចូលមើល៖ https://www.mass.gov/pesticide- examination-and-licensing.

## ក្រុមហ៊ុនដែលល្អនឹង...

- ចុះធ្វើអធិការកិច្ចដល់កន្លែងរបស់អ្នក មុននឹងចេញតម្លៃប៉ាន់ស្មានឲ្យអ្នក។
- ផ្តល់ជូនអ្នកនូវរបាយការណ៍ចុះអធិការកិច្ចជាលាយលក្ខណ៍អក្សរ និងផែនការសកម្មភាព។
- យោងលើតម្លៃប៉ាន់ស្មាននោះ និងផែនការកម្ចាត់សត្វល្អិតដែលបានពីលទ្ធផលនៃការរកឃើញនោះ នឹងផ្តល់សេវាទៅតាមតម្រូវការជាក់ស្តែងផ្ទាល់ខ្លួន។
- ផ្តល់ដំបូន្មានឲ្យទៅរកអ្នកជំនាញឯទៀតផ្នែកជួសជុលធំៗ បើចាំបាច់។
- ចុះទៅមើលជាញឹកញាប់ រហូតដល់ការងារនេះចប់សព្វគ្រប់។
- ដាក់នុយថ្នាំពុលនៅក្នុងប្រអប់សុវត្ថិភាពត្រឹមត្រូវ។
- ជួលអ្នកកម្ចាត់សត្វល្អិតដែលមានជំនាញត្រឹមត្រូវ និងឆ្លងកាត់វគ្គបណ្តុះបណ្តាល។
- ពន្យល់ណែនាំអ្នកអំពីរបៀបបង្ការសត្វកណ្តុរ។

## ការសហការ

- ចូរដើរជាមួយអ្នកជំនាញខាងគ្រប់គ្រងសត្វល្អិត ក្នុងពេលដែលពួកគាត់ចុះមកម្តងៗ និងត្រូវកត់ត្រាការងារជាបន្តបន្ទាប់។
- ព្រមព្រៀងគ្នាលើផែនការសេវា និងថ្លៃសេវា។

**តើអ្នកជាម្ចាស់គេហដ្ឋានឬ? តើអ្នករស់នៅគេហដ្ឋាននោះឬ? តើគេហដ្ឋាននោះមានបន្ទប់បី ឬច្រើនជាងនេះ?**

បើអ្នកឆ្លើយបាទ/ចាស ទៅនឹងសំណួរទាំងនេះ មានន័យថាអ្នកមានសិទ្ធិទទួលបានកម្មវិធីជួយគ្រប់គ្រងសត្វចង្រៃតាមគេហដ្ឋានរបស់ទីក្រុងឡូវែល!

កម្មវិធីនេះផ្តល់នូវសេវាអធិការកិច្ច និងនុយថ្នាំបំពុលដោយឥតគិតថ្លៃ។ កម្មវិធីនេះផ្តល់ជូនដោយផ្នែកសេវាអភិវឌ្ឍន៍របស់សាលាក្រុងឡូវែល។ មន្ត្រីអធិការកិច្ចផ្នែកសុខាភិបាលរបស់សាលាក្រុង និងអ្នកកម្ចាត់សត្វចង្រៃដែលមានអាជ្ញាប័ណ្ណរបស់រដ្ឋ នឹងចុះមើលទីតាំងរបស់អ្នក លុបរូងក្នុងដី និងដាក់ប្រអប់ដាក់នុយថ្នាំបំពុល។ ពួកគេនឹងវិលទៅមើលទីតាំងនោះរាល់សប្តាហ៍ រហូតដល់សត្វចង្រៃនៅលើទីតាំងនោះថយចុះ។

# រឿងនិទៀន និងរឿងពិតអំពីសត្វកណ្តុរ

1. **រឿងនិទៀន៖** សត្វកណ្តុរទំហំប៉ុនឆ្មាមាននៅទីក្រុងឡូវែល។
   **រឿងពិត៖** សត្វកណ្តុរស្ទើរតែទាំងអស់ នៅក្នុងតំបន់របស់យើង មានទម្ងន់មិនលើពីមួយផោន។ កាលណាសត្វនេះខ្លាច វានឹងបំប៉ះរោមរបស់វាឡើង ដែលមើលទៅដូចជាធំជាងធម្មតា នោះគ្រាន់តែដើម្បីវាកំញើញសត្រូវរបស់វាប៉ុណ្ណោះ។
2. **រឿងនិទៀន៖** "ក្រុងកណ្តុរ" មាននៅក្នុងលូទឹកស្អុយរបស់យើង។
   **រឿងពិត៖** មានសត្វកណ្តុរមួយចំនួនតូចប៉ុណ្ណោះ ដែលរស់នៅក្នុងលូទឹកស្អុយ។ សត្វកណ្តុរស្ទើរតែទាំងអស់ រស់នៅក្នុងរូងក្នុងដី ឬនៅជាន់ក្រោមដី។
3. **រឿងនិទៀន៖** សត្វកណ្តុរ"ធន់"នឹងថ្នាំពុល។
   **រឿងពិត៖** ថ្នាំពុលសម័យនេះមានប្រសិទ្ធភាពសម្លាប់សត្វកណ្តុរ–ប៉ុន្តែទាល់តែសត្វកណ្តុរស៊ីវាដែរ។ កាលណាសម្រាមងាយស្រួលឲ្យកណ្តុរចូលបាន វាមិនស៊ីនុយពុលនោះទេ។
4. **រឿងនិទៀន៖** មានសត្វកណ្តុរច្រើនប្រភេទរស់នៅក្នុងក្រុងឡូវែល។
   **រឿងពិត៖** មានតែសត្វកណ្តុរប្រភេទន័រវេប៉ុណ្ណោះ ដែលរស់នៅទីនេះ។ សត្វប្រភេទនេះមានច្រើនពណ៌ និងទំហំខុសៗគ្នា អាស្រ័យលើអាយុកាលរបស់វា និងកន្លែងដែលវារស់នៅ។ ជាលទ្ធផល មនុស្សហៅឈ្មោះវាខុសៗគ្នា (កណ្តុរក្រុង
   កណ្តុរត្នោត កណ្តុរលូ កណ្តុរផែ កណ្តុរទន្លេ កណ្តុរឡើងហែម កណ្តុរផ្ទះ)។
   កណ្តុរទាំងនេះមានពូជតែមួយ។
5. **រឿងនិទៀន៖** ឆ្មា ឆ្កែ ឥន្ទ្រី និងសត្វដទៃទៀត ជួយចាប់កណ្តុរក្រុង។
   **រឿងពិត៖** សត្វទាំងនេះអាចសម្លាប់កណ្តុរម្តងម្កាលបាន។ ប៉ុន្តែវាមិនអាចសម្លាប់សត្វកណ្តុរដែលបង្កើតកូនថៅយ៉ាងលឿនបាននោះទេ។ **មានតែមនុស្សប៉ុណ្ណោះទើបអាចចាត់ការរឿងនេះបាន!**

សម្រាប់ព័ត៌មានបន្ថែម៖
www.lowellma.gov/1689/Rodent-Control

ដើម្បីរាយការណ៍អំពីសកម្មភាពកណ្តុរ
សូមអ៊ីម៉ែលទៅ៖
rodents@lowellma.gov ឬទូរស័ព្ទ៖
**978-674-4144**